# សន្និបាតបូកសរុបលទ្ធផលការងារ
# ប្រចាំឆ្នាំ២០២៥ និង ទិសដៅអនុវត្តឆ្នាំ២០២៦
## ក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា អាជ្ញាធរទន្លេសាប

# លទ្ធផលការងារប្រចាំ២០២៥ និង ទិសដៅអនុវត្តឆ្នាំ២០២៦

## អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល



# មាតិកា

១ សេចក្ដីផ្ដើម

២ លទ្ធផលការងារ

ក.ការងារគ្រប់គ្រងរដ្ឋបាលទូទៅ

ខ.ការងារហិរញ្ញវត្ថុ

គ.ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

ឃ. ការងារមជ្ឈមណ្ឌលសេវាបច្ចេកទេស ប្រព័ន្ធធារាសាស្ត្រ ឧតុនិយម

ង.សមិទ្ធផលរចនាសម្ព័ន្ធរឹង

៣ ការងារបន្ត

៤ បញ្ហាប្រឈម

៥ សន្និដ្ឋាន

## ១ សេចក្តីផ្តើម

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងបានរំលេចទ្បើងនូវវិស័យធនធានទឹក ដែលជាបេសកកម្មសំខាន់មួយរបស់ក្រសួងធនធានទឹក និងឧតុនិយម។ រយៈពេលមួយឆ្នាំកន្លងមក គិតចាប់ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០២៥ នៃការអនុវត្តការងាររបស់ក្រសួង សម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន។ ជាទីមោទនភាពតាមរយៈការរួមចំណែកពីគ្រប់ផ្នែកទាំងអស់របស់ក្រសួង ក្រោមការដឹកនាំដ៏ឈ្លាសវៃ មោះមុតរបស់ឯកឧត្តម **ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល ក៏បានរួមចំណែកយ៉ាងសំខាន់ និងបានបំពេញភារកិច្ចក្នុងការដឹកនាំ សម្របសម្រួល រៀបចំកិច្ចការអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល ដែលទទួលបានលទ្ធផលដូចតទៅ៖

## ២ លទ្ធផលសម្រេចបាន

### ក.ការងារគ្រប់គ្រងរដ្ឋបាលទូទៅ

អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល មាននាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្សជាសេនាធិការ សម្រេចបានលទ្ធផលដូចតទៅ៖

- ការងារអភិបាលកិច្ច បានរៀបចំ និងបង្កើត
  - គណៈកម្មការវាយតម្លៃការតែង និងបញ្ចប់មុខដំណែងមន្ត្រីរាជការក្រសួងធនធានទឹក និងឧតុនិយម
  - គណៈកម្មការគ្រប់គ្រងប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈរបស់ក្រសួង
  - គណៈកម្មាធិការលើកម្ពស់អភិបាលកិច្ចក្រសួង
  - គណៈកម្មការសិទ្ធិមនុស្សក្រសួង
  - គណៈកម្មការគ្រប់គ្រងប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈរបស់ក្រសួង
  - គណៈកម្មការតម្រង់ទិសសម្រាប់គម្រោងស្តារ និងគ្រប់គ្រងអាងស្តុកទឹកស្វាយចេក

## ២ លទ្ធផលសម្រេចបាន

**ក.ការងារគ្រប់គ្រងរដ្ឋបាលទូទៅ(ត)**

- ការងារអភិបាលកិច្ច(ត)
  - សម្របសម្រួលគ្រប់ផ្នែកទាំងអស់របស់ក្រសួង និងទំនាក់ទំនងរវាងក្រសួង-ស្ថាប័ន បានល្អប្រសើរ និងមានប្រសិទ្ធភាព
  - គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួងបានរលូន និងទាន់ពេលវេលា
  - កែទម្រង់បែបបទ និងនីតិវិធីរដ្ឋបាលស្មុគស្មាញមួយចំនួនឱ្យមានភាពរលូនតាមការណែនាំរបស់ឯកឧត្តមរដ្ឋមន្ត្រី
  - ផែនការអភិវឌ្ឍន៍ធនធានមនុស្សរបស់ក្រសួងបានចំគោលដៅ
  - ការងារដឹកនាំអង្គភាព ការគ្រប់គ្រងមន្ត្រីរាជការ ផ្ទាំទំនប់ នៅតាមមន្ទីរធនធានទឹក និងឧតុនិយមត្រូវបានសម្របសម្រួលបានល្អប្រសើរ
  - កិច្ចប្រជុំនានារបស់ថ្នាក់ដឹកនាំ និងកម្មវិធីផ្លូវការនានារបស់ឯកឧត្តមរដ្ឋមន្ត្រីមានការរៀបចំ និងសម្របសម្រួលបានត្រឹមត្រូវ

## ២ លទ្ធផលសម្រេចបាន

### ក.ការងារគ្រប់គ្រងរដ្ឋបាលទូទៅ(ត)

- ការងារអភិបាលកិច្ច(ត)
  - ចូលរួមរៀបចំសន្និបាតបូកសរុបការងារ ក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងអាជ្ញាធរទន្លេសាបបានលទ្ធផលគួរជាទីមោទនៈ
  - ពិធីតាំងពិពណ៌ផ្សព្វផ្សាយទិវាទឹក និងឧតុនិយមពិភពលោកបានទទួលការស្វាគមន៍ពីសិស្ស និស្សិត និងមហាជន
  - រៀបចំបុណ្យជាតិ-អន្តរជាតិនានាតាមគោលការណ៍របស់គណៈកម្មការរៀបចំបុណ្យជាតិ-អន្តរជាតិបានទាន់ពេលវេលា
  - ការងារចុះអនុស្សរនៈនៃការយោគយល់គ្នាជាមួយធនាគារ វិទ្យាស្ថាន និងដៃគូរអភិវឌ្ឍន៍នានា
  - ផ្សព្វផ្សាយលើសារាចរ សេចក្តីណែនាំ សេចក្តីជូនដំណឹង សេចក្តីសម្រេច ផ្សេងៗបានទូលំទូលាយ
  - មន្ត្រីរាជការ ថ្នាក់ដឹកនាំ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីបុណ្យនានា ត្រូវបានចាត់តាំងឱ្យចូលរួមតាមការអញ្ជើញ។

## ២ លទ្ធផលសម្រេចបាន

### ក.ការងារគ្រប់គ្រងរដ្ឋបាលទូទៅ (ត)

- ការងារគ្រប់គ្រងធនធានមនុស្ស
  - ការងារស្នើសុំដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ជូនមន្ត្រីរាជការស៊ីវិល នៃក្រសួងធនធានទឹក និងឧតុនិយម
  - ការងារស្នើសុំគ្រឿងឥស្សរិយយសផ្តល់ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា
  - ការងាររៀបចំបែបបទ នីតិវិធីតាំងស៊ប់ ចូលនិវត្តន៍ ទំនេរគ្មានបៀវត្ស ផ្ទេរមន្ត្រី មរណភាព ស្វ័យប្រកាស មន្ត្រីជាប់កិច្ចសន្យា តែងតាំង វិញ្ញាបនបត្ររដ្ឋបាលជូនមន្ត្រីរាជការក្រសួងធនធានទឹក និងឧតុនិយម
  - ការងារសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ ក្នុងបរិវេណទីស្តីការក្រសួងធ្វើបានយ៉ាងល្អ
  - បច្ចុប្បន្នភាពសៀវភៅស្ថិតិក្របខ័ណ្ឌមុខងារសាធារណៈសម្រាប់ក្រសួង

## ២ លទ្ធផលសម្រេចបាន

### ក.ការងារគ្រប់គ្រងរដ្ឋបាលទូទៅ (ត)

- ការងារគ្រប់គ្រងធនធានមនុស្ស
  - បានពិនិត្យ និងរៀបចំតារាងឧបសម្ព័ន្ធស្តីពីការបែងចែកមន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីផ្ទាំទំនប់សម្រាប់ផែនការឆ្នាំ២០២៦
  - រៀបចំសៀវភៅស្តីពីនីតិវិធីរដ្ឋបាល និងបណ្ណាល័យ
  - ធ្វើបច្ចុប្បន្នភាពប័ណ្ណសមាជិក ប.ស.ស ថ្មីជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា
  - បានបញ្ជូនមន្ត្រីរាជការចូលរួមវគ្គបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេសបានចំនួន ៧៤៣នាក់ ក្នុងនោះមានស្ត្រីចំនួន ២២២នាក់
  - ទទួលភារកិច្ចផ្សេងៗតាមបញ្ជាឯកឧត្តមរដ្ឋមន្ត្រី។

## ២ លទ្ធផលសម្រេចបាន

### ក.ការងារគ្រប់គ្រងរដ្ឋបាលទូទៅ (ត)

- ការងារកំណែទម្រង់សាធារណៈ
  - បាននឹងកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
  - រៀបចំសៀវភៅណែនាំស្តីពីការតាក់តែងលិខិតរដ្ឋបាលក្រសួង
  - ធ្វើបច្ចុប្បន្នភាពលើទិន្នន័យលើមុខដំណែងក្នុងក្របខណ្ឌ ក.ខ.គ មន្រ្តីរាជការនៅក្រសួង និងមន្ទីរទូទាំងប្រទេស
  - បានពិនិត្យ និងធ្វើបច្ចុប្បន្នភាពរៀបចំសៀវភៅស្ថិតិក្របខ័ណ្ឌមុខងារសាធារណៈទាំង១២ខែ ឆ្នាំ២០២៥ សម្រាប់ថ្នាក់ដឹកនាំ និងមន្រ្តីរាជការក្រសួង
  - ទទួលភារកិច្ចផ្សេងៗតាមបញ្ជាឯកឧត្តមរដ្ឋមន្រ្តី។

## ២ លទ្ធផលសម្រេចបាន

### ខ.ការងារគ្រប់គ្រងហិរញ្ញវត្ថុ

- ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ២០២៥-២០២៧
- បានធ្វើរបាយការណ៍ចំណាយថវិកាប្រចាំឆ្នាំ២០២៥របស់ក្រសួង
- បានចុះកិច្ចព្រមព្រៀងសមិទ្ធកម្មឆ្នាំ២០២៥រវាងក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានបញ្ចូលផែនការចំណាយសាច់ប្រាក់ប្រចាំឆ្នាំក្នុងប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់របស់អគ្គនាយកដ្ឋានរតនាគារជាតិទាន់ពេលវេលា
- បានរៀបចំតារាងប្រៀបធៀបកើន-ថយ ចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២៥ និងបានបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

## ២ លទ្ធផលសម្រេចបាន

### ខ.ការងារគ្រប់គ្រងហិរញ្ញវត្ថុ(ត)

ក្នុងអាណត្តិនីតិកាលទី៧នេះ ក្រសួងបានអនុវត្តបន្តនូវគោលនយោបាយ ដំណាក់កាលទី៤ ការកសាងគណនេយ្យភាពសមិទ្ធកម្ម ការបង្កើនប្រសិទ្ធភាពការគ្រប់គ្រង និងអនុវត្តថវិកា ដែលទទួលបានលទ្ធផលដូចតទៅ៖

**១.កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- រៀបចំផែនការសកម្មភាពលម្អិត KPIs ឆ្នាំ២០២៥ និងបានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសបញ្ជូនទៅក្រសួងសេដ្ឋកិច្ចទាន់ពេលវេលា
- បាននឹងកំពុងប្រមូលធាតុចូលដើម្បីរៀបចំសេចក្តីព្រាងផែនការសកម្មភាពរួមសម្រាប់អនុវត្តបច្ចុប្បកម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ២០២៥-២០២៨ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងផ្តល់យោបល់
- បាននឹងកំពុងកែសម្រួលសេចក្តីព្រាងចុងក្រោយរបាយការណ៍លទ្ធផលនៃការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសម្រាប់ឆ្នាំ២០២៤តាមការផ្តល់យោបល់របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ២ លទ្ធផលសម្រេចបាន

### ខ.ការងារគ្រប់គ្រងហិរញ្ញវត្ថុ(ត)

២. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)

- បានកត់ត្រាមុខងារវិភាជន៍ថវិកា(BA) ក្នុងប្រព័ន្ធ FMIS រួមមាន ក)ការព្រៀករដ្ឋទេយ្យបុរេប្រទានដើមឆ្នាំ២០២៥ និង ខ)និយ័តកម្មផ្ទៃក្នុងសម្រាប់ឆ្នាំ២០២៥
- បានបញ្ចូលអាណត្តិទូទាត់ត្រង់ចំណាយកិច្ចលទ្ធកម្ម ចំណាយបន្ទុកបុគ្គលិក រដ្ឋទេយ្យបុរេប្រទាន ជានាការចំណាយ និងចំណាយដែលមានហានិភ័យទាប (ទឹក ភ្លើង ពន្ធផ្លូវ)
- បានបញ្ចូល ក)ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៧ ខ)គម្រោងចំណាយប្រាក់បៀវត្សមន្ត្រីរាជការ និង គ)គម្រោងចំណាយថវិកាប្រចាំឆ្នាំ២០២៦ក្នុងប្រព័ន្ធរៀបចំផែនការថវិកា (BPS)

## ២ លទ្ធផលសម្រេចបាន

### ខ.ការងារគ្រប់គ្រងហិរញ្ញវត្ថុ(ត)

**២. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)(ត)**

- បានកត់ត្រាត្រឹមត្រូវចំណូលនៅក្នុងមុខងារគណនីត្រូវទារ (AR)
- បានបញ្ជូនតំណាងនាយកដ្ឋានហិរញ្ញវត្ថុធ្វើបទបង្ហាញចែករំលែកបទពិសោធន៍នៃការចូលរួមអនុវត្ត FMIS ប្រចាំក្រសួងធនធានទឹក និងឧតុនិយម ដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ នៅសណ្ឋាគារសាំងគ្រីឡា។

## ២ លទ្ធផលសម្រេចបាន

### គ.ការងារផែនការ

- ការរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងផែនការអភិវឌ្ឍន៍ជាតិ (២០២៤-២០២៨)
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយម រយៈពេល ៥ឆ្នាំ (២០២៤-២០២៨) របស់ក្រសួងដែលបានបង្ហាញពីគោលបំណង គោលដៅ យុទ្ធសាស្ត្រ និងសកម្មភាពនានាស្តីពីការគ្រប់គ្រងអភិវឌ្ឍន៍ធនធានទឹក និងឧតុនិយម និងបញ្ជូនទៅក្រសួងផែនការ ទីស្តីការគណៈរដ្ឋមន្ត្រីទាន់ពេលវេលា

## ២ លទ្ធផលសម្រេចបាន

### គ.ការងារផែនការ (ត)

- គម្រោងកម្មវិធីវិនិយោគសាធារណៈ (PIP) ៣ឆ្នាំរំកិល របស់ក្រសួង ត្រូវបានរៀបចំរួចផ្ញើទៅជូនក្រសួងផែនការទាន់ពេលវេលា
- កសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធនធានទឹក រយៈពេល៥ឆ្នាំ(២០២៤-២០២៨) បានបន្តកែលម្អឱ្យកាន់តែចំគោលដៅ
- ការត្រួតពិនិត្យតាមដាន និងវាយតម្លៃរាល់ការអនុវត្តគម្រោងទាំងថវិកាជាតិ និងទាំងថវិកាដៃគូអភិវឌ្ឍន៍ (M&E) នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយមនៅក្នុងក្របខ័ណ្ឌ ទូទាំងប្រទេស ត្រូវបានអនុវត្ត
- ការងារដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យធនធានទឹកនិងឧតុនិយម ដើម្បីជាមូលដ្ឋានបង្អែកសម្រាប់កសាង ផែនការ និងអនុវត្តន៍ផែនការត្រូវបានត្រួតពិនិត្យ

## ២ លទ្ធផលសម្រេចបាន

### គ.ការងារផែនការ (ត)

- សមត្ថភាពលើការប្រមូល និងធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិប្រព័ន្ធជារាសាស្ត្រ និងការរៀបចំផែនទីក្នុងកម្មវិធី CISIS នៅតាមបណ្តាខេត្ត ត្រូវបានចុះពង្រឹង
- កិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ ប្រទេសផ្តល់ជំនួយ និងដៃគូរអភិវឌ្ឍន៍នានាបានកំពុងបន្តសហការយ៉ាងល្អប្រសើរ
- សម្របសម្រួលជំនួយពីដៃគូរអភិវឌ្ឍន៍អន្តរជាតិលើវិស័យធនធានទឹកដើម្បីចងក្រងក្នុងរបាយការណ៍វឌ្ឍនៈភាពប្រចាំឆ្នាំ
- ការយល់ដឹងអំពីអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ
- ផែនការយុទ្ធសាស្រ្តថវិកាពផ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំ២០២៦ របស់ គ.ជ.អ.ប ត្រូវបានរៀបចំបញ្ចូលក្នុងផែនការរួមរបស់ក្រសួង

## ២ លទ្ធផលសម្រេចបាន

### គ.ការងារផែនការ(ត)

បានបូកសរុបរបាយការណ៍ប្រចាំខែ នីមួយៗ ត្រីមាស ឆមាស ១២ខែ ឆ្នាំ២០២៥ របស់ក្រសួង សម្រាប់ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងថ្នាក់ដឹកនាំក្នុងក្រសួង ព្រមទាំងជូនដល់បណ្តានាយកដ្ឋានក្រោមឱវាទក្រសួង ដើម្បីឯកសារ ដែលរួមមាន៖

- ☞ របាយការណ៍សរុបតាមបណ្តានាយកដ្ឋានទាំង ១២
- ☞ របាយការណ៍សរុបតាមបណ្តារាជធានី-ខេត្ត ទាំង២៥
- ☞ ការពិនិត្យតាមដាន វាយតម្លៃដល់ទីតាំងគោលដៅ
- ☞ ការងារទាំងនេះសម្រេចបាន ១០០% ទាន់ពេលវេលាជាប្រចាំ។

## ២ លទ្ធផលសម្រេចបាន

### ឃ.ការងារមជ្ឈមណ្ឌលសេវាបច្ចេកទេស ប្រព័ន្ធធារាសាស្ត្រ ឧត្តមនិយម (TSC)

– **ការអភិវឌ្ឍធនធានមនុស្សលើវិស័យធនធានទឹក**

មន្ត្រីរាជការប្រមាណ១៨០រូប ត្រូវបានបណ្តុះបណ្តាលដោយមជ្ឈមណ្ឌល TSC ទាំងថ្នាក់ជាតិ និងថ្នាក់រាជធានីខេត្ត ដែលក្នុងនោះរួមមាន៖

- ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ
- គោលការណ៍ណែនាំស្តីពីការប្រើប្រាស់ និងគ្រប់គ្រងទឹកតាមអាងស្តុក
- ការពង្រឹងគណៈកម្មាធិការ ស.ទ.ប.ក ប្រព័ន្ធធារាសាស្ត្រលំហាច និងលើការគ្រប់គ្រងការថែទាំ
- ការបញ្ជូលមន្ត្រីរាជការចូលរួមវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលានៅក្រៅប្រទេសដើម្បីបង្កើនសមត្ថភាពបន្ថែម។

## ២ លទ្ធផលសម្រេចបាន

### ឃ.ការងារមជ្ឈមណ្ឌលសេវាបច្ចេកទេស ប្រព័ន្ធធារាសាស្ត្រ ឧតុនិយម (ត)

- ការងារសិក្សាស្រាវជ្រាវ
  - បានជ្រើសរើសទីតាំង និងតម្លើងឧបករណ៍តម្រូវការទឹករបស់ដំណាំស្រូវ វាស់ដោយដៃចំនួន ៣ កន្លែង (ខេត្តកណ្ដាល ១កន្លែង និងខេត្តកំពង់ស្ពឺ ២ កន្លែង)
  - ទិន្នន័យតម្រូវការទឹករបស់ដំណាំស្រូវក្នុងខេត្តតាកែវ កណ្ដាល កំពង់ស្ពឺ ព្រៃវែង កំពង់ចាម សៀមរាប និងខេត្តបន្ទាយមានជ័យ ចាប់ពីពាក់កណ្ដាលខែកុម្ភៈ ឆ្នាំ២០២៥ រហូតដល់ពាក់កណ្ដាលខែធ្នូ ឆ្នាំ២០២៥ត្រូវបានកត់ត្រា និងប្រមូលចងក្រង
  - ប៉ុស្តិ៍តម្រងទឹកភ្លៀងត្រូវបានជួសជុល និងថែទាំលើកទី១ ក្នុងខែឧសភា ឆ្នាំ២០២៥ និងលើកទី២ ក្នុងខែតុលា ឆ្នាំ២០៥។

## ② លទ្ធផលសម្រេចបាន

### ឃ.ការងារមជ្ឈមណ្ឌលសេវាបច្ចេកទេស ប្រព័ន្ធធារាសាស្ត្រ ឧត្តុនិយម (ត)

– **ការសហការជាមួយគម្រោងសហប្រតិបត្តិការដៃគូ**

ដើម្បីបង្កើនសមត្ថភាពមន្ត្រីលើវិស័យធនធានទឹក មជ្ឈមណ្ឌលបានសហការជាមួយដៃគូអភិវឌ្ឍន៍នានារួមមាន៖

- Japan Water Agency លើការងារតម្លើងឧបករណ៍ Paddich ដើម្បីសិក្សាស្រាវជ្រាវពីការកាត់បន្ថយការបំភាយឧស្ម័នមេតាន និងការបង្កើនទិន្នផលស្រូវ
- លទ្ធផលគម្រោងស្តង់ដាជាតិប្រព័ន្ធធារាសាស្ត្រ NaSDeP របស់ទីភ្នាក់ងារជប៉ុន (JICA) ដោយបានបណ្តុះបណ្តាលមន្ត្រីថ្នាក់ជាតិ និងថ្នាក់រាជធានីខេត្តសរុប ២៤៤ រូប
- ចូលរួមជាមន្ត្រីសមភាគីគម្រោងស្តារឡើងវិញប្រព័ន្ធស្រោចស្រព និងដោះទឹកភាគនារតីរាជធានីភ្នំពេញ (CP-P14&CP-P28)។

## ២ លទ្ធផលសម្រេចបាន

### ខ.សមិទ្ធផលរចនាសម្ព័ន្ធ

- ក្នុងឆ្នាំ២០២៥ ចំណតរថយន្ត សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ និងលាបថ្នាំអគារ និងបង្កើនសោភណ្ឌភាព និងបែងចែកការប្រើប្រាស់បន្ទប់ដល់ថ្នាក់ដឹកនាំ និងនាយកដ្ឋានបានរៀបរយល្អ
- ទីធ្លាត្រូវបានចាក់ដី និងថ្ម ហើយបានដាក់ភ្លើងបំភ្លឺក្នុងបរិវេណទីស្តីការក្រសួង
- រៀបចំបដា ពាក្យស្លោក និងតាំងព្រះឆាយាល័ក្ខណ៍ ដងទង់ជាតិ
- រចនា ជួលជុល ថែទាំ ផ្នែកខាងក្នុងសាលប្រជុំ ឧបករណ៍អេឡិចត្រូនិច និងមិនមែនអេឡិចត្រូនិច
- សាលប្រជុំដើមត្នោតបានជួសជួលរួចរាល់ជាស្ថាពរ

## ៣ ការងារបន្ត

អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល នឹងបន្តខិតខំអនុវត្តការងារសំខាន់ៗ ដូចខាងក្រោម៖

- បន្តកែលម្អការចរាចរឯកសាររដ្ឋបាលតាមប្រព័ន្ធព័ត៌មានវិទ្យា និងប្រព័ន្ធរដ្ឋបាលតែមួយ
- ដាក់ឱ្យអនុវត្តសេចក្ដីណែនាំស្ដីពីបែបបទនៃការតាក់តែងលិខិតរដ្ឋបាលក្រសួង ឱ្យមានស្តង់ដាតែមួយ
- រៀបចំវគ្គបណ្ដុះបណ្ដាល និងបង្កើតកម្មវិធីបណ្ដុះបណ្ដាលថ្មីៗដល់មន្ត្រីរាជការ ដោយកៀរគរថវិកា ពីដៃគូអភិវឌ្ឍន៍នានា ដើម្បីអភិវឌ្ឍធនធានមនុស្សលើវិស័យធនធានទឹកបន្ថែមទៀត
- សហការ សម្របសម្រួល រៀបចំធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តក្រសួង និងធ្វើកំណែទម្រង់រដ្ឋបាលឱ្យកាន់តែមានប្រសិទ្ធភាព

# ៣ ការងារបន្ទ (ត)

- នឹងរៀបចំដឹកនាំ ការងារបណ្តុះបណ្តាលមន្ត្រីរាជការក្រសួងធនធានទឹក និងឧតុនិយមទាំងថ្នាក់កណ្តាល និងរាជធានី-ខេត្ត លើការងាររដ្ឋបាល ហិរញ្ញវត្ថុ និងបច្ចេកទេស
- បន្តសម្របសម្រួលការងារជាមួយគ្រប់អង្គភាពចំណុះក្រសួង
- គ្រោងនឹងអនុវត្ត គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMM) របស់ក្រសួងនៅត្រីមាសទី៤ ឆ្នាំ២០២៥
- គ្រោងរៀបចំ អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស ដែលជាអង្គភាពថវិកាអណាប័កផ្ទេរសិទ្ធិមិនពេញលេញឱ្យទៅជាអង្គភាពថវិកាអណាប័កផ្ទេរសិទ្ធិពេញលេញនៅឆ្នាំ២០២៧
- អនុវត្តការងារដែលឯកឧត្តមរដ្ឋមន្ត្រីប្រគល់ជូន។

# ៤ បញ្ហាប្រឈម

ទន្ទឹមនឹងការអនុវត្តការងារកន្លងមក អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល បានជួបបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម៖

- ថវិកាសម្រាប់បណ្តុះបណ្តាលធនធានមនុស្សផ្នែកបច្ចេកទេសទទួលបានតិចតួចពីថវិការដ្ឋ និងតិចតួចបំផុតពីដៃគូរអភិវឌ្ឍន៍ និងមានតែសម្រាប់រយៈពេលខ្លី
- ការកសាងផែនការអភិវឌ្ឍធនធានមនុស្សបន្តវេន នៅជាបញ្ហាធំសម្រាប់ការអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយម
- ខ្វះធនធានមនុស្សមានសមត្ថភាពទាំងផ្នែកបច្ចេកវិទ្យា ភាសាបរទេស ច្បាប់ រដ្ឋបាល និងបច្ចេកទេសធនធានទឹក ឧតុនិយម ធារាសាស្ត្រ ជលសាស្ត្រ សំណង់ស៊ីវិល ទឹកក្រោមដី។ល។
- មន្ត្រីបច្ចេកទេសចាស់ៗចាប់ផ្តើមចូលនិវត្តន៍បណ្តើរៗ។

## ៥ សន្និដ្ឋាន

- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល សម្រេចបាននូវសមិទ្ធផលភាគច្រើនសុទ្ធសឹងតែជាផ្នែកទន់ ហើយមិនអាចវាស់វែងបាន ឬរាប់ជាតួលេខបាន
- សមិទ្ធផលទាំងទន់ និងរឹង ដែលសម្រេចបានជាច្រើនរយៈពេល១២ខែក្នុងការអនុវត្ត ដោយអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល សម្រេចទៅបានតាមរយៈការសហការ ជួយជ្រោមជ្រែងពីគ្រប់នាយកដ្ឋានជំនាញដែលជាសេនាធិការ និងមន្ត្រីរាជការក្រោមឱវាទក្រសួង
- សូមវាយតម្លៃខ្ពស់ពីការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត និងការលះបង់របស់មន្ត្រីទាំងអស់ ដោយមិនគិតពីការនឿយហត់។

# សកម្មភាពចុះណែនាំនីតិវិធីរដ្ឋបាលនៅតាមបណ្ដាលមន្ទីរធនធានទឹក និងឧតុនិយម














# សកម្មភាពដឹកនាំកិច្ចប្រជុំនៅទីស្តីការក្រសួងធនធានទឹក និងឧតុនិយម (ក្បាលថ្នល់)










# សកម្មភាពក្នុងពិធីចុះអនុស្សារណៈរវាងក្រសួងធនធានទឹក និងឧតុនិយម និងធនាគារ អភិវឌ្ឍន៍ជនបទ និងកសិកម្ម










# សកម្មភាពចូលរួមកិច្ចប្រជុំនានាសម្រាប់ឆ្នាំ២០២៥









# សូមអរគុណ!